**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណីលេខ: ៤១២ ប.អ.ស

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

**សាលក្រមលេខ:** ០២ "ថ"/៥៦

ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃអង្គារ ០២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

**ដើមចោទ ៖** ឈ្មោះ [redacted] គឹមមួយ ភេទស្រី អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅភូមិ [redacted] ។

**អ្នកតំណាងដោយអាណត្តិ ៖**លោក [redacted] អត្តលេខ ២៥៧៤T ជាមេធាវីនៃការិយាល័យ [redacted] មានអាសយដ្ឋាននៅអគារ [redacted] ។

**ចុងចម្លើយ ៖** ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាននៅផ្លូវ [redacted] ។

**អ្នកតំណាងដោយអាណត្តិ ៖** លោក [redacted] អត្តលេខ ៣១៧ និងលោក [redacted] អត្តលេខ ២៤៨៧T ជាមេធាវីនៃការិយាល័យមេធាវី [redacted] មានអាសយដ្ឋាននៅ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖**

ក.១.បង្គាប់ឱ្យចុងចម្លើយទូទាត់សងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

ក.២.បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

ក.៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ ៖**

**ខ.១.ការសង្ខេបអំពីរឿងក្តី ៖**

កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ដើមចោទឈ្មោះ [redacted] គីមមួយ និងចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន បានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៥១ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាសហព័ទ្ធរវាងដើមចោទ និងចុងចម្លើយ ពុំមានភាពចុះសម្រុងនឹងគ្នា ដែលជាហេតុធ្វើឱ្យដើមចោទបានដាក់ពាក្យបណ្តឹងលែងលះពីចុងចម្លើយ ។ ក្រោយមកនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ សាលាដំបូងខេត្តសៀមរាប បានចេញសាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ដោយក្នុងខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់បានសម្រេចពាក់ព័ន្ធនឹងបំណុលរួម គឺឱ្យដើមចោទឈ្មោះ[redacted]គីមមួយ និងចុងចម្លើយឈ្មោះ[redacted]ប៊ុនធឿន សងបំណុលពាក់កណ្តាលម្នាក់ដែលបានជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងបំណុលក្រៅពីជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានចំនួនសរុប ២៥.៩៥០ (ពីរម៉ឺនប្រាំពាន់ប្រាំបួនរយហាសិប) ដុល្លារអាមេរិក ដោយហេតុថា ចាប់តាំងពីពេលដែលតុលាការបានសម្រេច និងសាលក្រមបានចូលជាស្ថាពរមក ចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ពុំបានអនុវត្តកាតព្វកិច្ចទេ ហើយដើមចោទមានកូនដែលត្រូវចិញ្ចឹមបីបាច់ថែរក្សា និងត្រូវប្រឹងរកប្រាក់សងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រហូតនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ដើមចោទបានបង់ផ្តាច់ប្រាក់ដែលបានជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតចប់សព្វគ្រប់ដែលមានទឹកប្រាក់សរុបចំនួន ៣៥.៩៣៤,២៥ (បីម៉ឺនប្រាំពាន់ប្រាំបួនរយសាមសិបបួន និងម្ភៃប្រាំសេន) ដុល្លារអាមេរិក តែម្នាក់ឯង ។

**ខ.២. ចំណុចវិវាទ ៖**

១.តើការទាមទាររបស់ដើមចោទ ឱ្យចុងចម្លើយទូទាត់សងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មានលក្ខណៈត្រឹមត្រូវឬទេ ?

២.តើការទាមទាររបស់ដើមចោទឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មានលក្ខណៈត្រឹមត្រូវឬទេ ?

**គ. ការអះអាងរបស់គូភាគី**

**គ.១.ការអះអាងរបស់ដើមចោទ**

-ដើមចោទឈ្មោះ [redacted] គីមមួយ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួនសុំរក្សាសេចក្តីថ្លែងការណ៍នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ និងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម ៖

១.បង្គាប់ឱ្យចុងចម្លើយទូទាត់សងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

២.បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ខ្លួនប្ដឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចដែលមានខ្លឹមសារដូចខាងក្រោម ៖

១.បង្គាប់ឱ្យចុងចម្លើយទូទាត់សងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

២.បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

គ.១.១.អំពីការទាមទារឱ្យចុងចម្លើយសងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ កូនក្ដីរបស់ខ្លួនបានលែងលះគ្នាពីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ហើយតុលាការបានសម្រេចឱ្យកូនក្ដីខ្លួន និងចុងចម្លើយសងបំណុលម្នាក់ពាក់កណ្ដាល ។ កូនក្ដីខ្លួនសុំទាមទារប្រាក់ចំនួន ១៧,៩៦៧.១២៥(មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក ពីចុងចម្លើយ ព្រោះតាំងពីពេលដែលចុងចម្លើយលែងលះជាមួយកូនក្ដីខ្លួន ចុងចម្លើយបានឈប់សងបំណុលធនាគារទាំងអស់ ហើយកូនក្ដីខ្លួនជាអ្នកទទួលបន្ទុកសងបំណុលទាំងអស់ថែមទាំងការប្រាក់ទៀតផង ។

គ.១.២.អំពីការទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០(មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន មិនអនុវត្តកាតព្វកិច្ចសងប្រាក់រហូតមកទល់បច្ចុប្បន្ន ធ្វើឱ្យដើមចោទខាតបង់ពេលវេលា និងសេវាកម្មផ្លូវច្បាប់ ។

គ.១.៣.អំពីការទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី

-លោក មេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] គឺមមួយ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ សុំកែប្រែចំណុចទាមទារប្រាក់ប្រដាប់ក្ដីជាបន្ទុកដើមចោទ ទៅជាប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ដោយហេតុថាកូនក្ដីរបស់ខ្លួនដែលជាដើមចោទមានការគេ័ន្ត្របេឡ ។

**គ.២.ការអះអាងរបស់ចុងចម្លើយ**

-ចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ខ្លួនសូមបដិសេធចំពោះសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ដោយហេតុថាតាំងពីខ្លួនបានលែងលះ

ជាមួយដើមចោទឈ្មោះ [redacted] គឹមមួយ ខ្លួនទទួលស្គាល់សាលក្រមនោះ ហើយខ្លួនពុំបានប្តឹងឧទ្ធរណ៍លើសាលក្រមនោះទេ ។ ម្យ៉ាងវិញទៀត នៅក្នុងសេចក្តីសម្រេចសាលក្រម ខ្លួនពុំបានចូលរួមសងបំណុលនោះទេ តែខ្លួនបានទុកប្រាក់ឈ្នួលផ្ទះ និងប្រាក់កក់ឱ្យដើមចោទសងធនាគារទាំងអស់ ។ ក្រោយពីបែកគ្នាខ្លួនពុំដែលបានប្រាប់អ្វីទៅដើមចោទនោះទេ ។

គ.២.១.អំពីការទាមទារឱ្យចុងចម្លើយសងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ សុំរក្សាសេចក្តីថ្លែងការណ៍នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ។ សូមបញ្ជាក់ថា បំណុលសរុបទាំងអស់បានមកពីការខ្ចីធនាគារចំនួន២លើក ដោយលើកទី១ ខ្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីយកទៅជួលផ្ទះ និងជួសជុលផ្ទះសម្រាប់ធ្វើអាជីវកម្ម និងលើកទី២ ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក កូនក្តីខ្លួនពុំបានចូលរួមខ្ចីនោះទេ ដោយហេតុថា សាច់ប្រាក់ដែលទទួលបានពីធនាគារ គឺវេរចូលទៅក្នុងគណនីផ្ទាល់ខ្លួនរបស់ដើមចោទតែម្នាក់ឯង ហើយប្រាក់នេះដើមចោទបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួនមិនមានអ្វីពាក់ព័ន្ធនឹងចុងចម្លើយនោះទេ ។ ជាមួយគ្នានេះដែរ នៅពេលដែលកិច្ចសន្យាជួលផ្ទះបានបញ្ចប់ កូនក្តីខ្លួនបានចាកចេញពីផ្ទះជួលដោយពុំបានយកអ្វីមកជាមួយនោះទេ ដោយទុកកុំព្យូទ័រចំនួន ១០ (ដប់) គ្រឿងឱ្យដើមចោទ ហើយកូនក្តីខ្លួនដែលជាចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន សុំមិនទទួលខុសត្រូវលើការសងបំណុលនោះទេ ដោយហេតុថា ពេលបញ្ចប់កិច្ចសន្យាជួលផ្ទះដើមចោទបានទទួលប្រាក់កក់ត្រឡប់មកវិញពីម្ចាស់ផ្ទះជួល ដែលមានចំនួន ៥.៤៣៧,៥១ (ប្រាំពាន់បួនរយសាមសិបប្រាំពីរ និងហាសិបមួយសេន) ដុល្លារអាមេរិក ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យាប្រគល់លុយផ្តាច់ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ។ លើសពីនេះ ដើមចោទទទួលបានប្រាក់ពីការជួលផ្ទះ៣ល្វែងចំនួន ៣៦ (សាមសិបប្រាំមួយ) ខែ ស្មើនឹងទឹកប្រាក់ចំនួន ១៦.២០០ (មួយម៉ឺនប្រាំមួយពាន់ពីររយ) ដុល្លារអាមេរិក ហើយដើមចោទទទួលបានការអនុគ្រោះពីម្ចាស់ផ្ទះជួលក្នុងមួយខែចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក ក្នុងរយៈពេល០៣ (បី) ឆ្នាំចុងក្រោយនេះ ដែលស្មើនឹងទឹកប្រាក់ចំនួន ៥.៤០០ (ប្រាំពាន់បួនរយ) ដុល្លារអាមេរិក ដោយសរុបទាំងអស់ដើមចោទទទួលបានប្រាក់ចំនួន ២៧.០៣៧,៥១ (ពីរម៉ឺនប្រាំពីរពាន់សាមសិបប្រាំពីរ និងហាសិបមួយសេន) ដុល្លារអាមេរិក ដែលចំនួនទឹកប្រាក់សរុបនេះគឺលើសពីចំនួនប្រាក់ដែលដើមចោទបានទាមទារទៅទៀត ។ បន្ទាប់ពីតុលាការចេញសាលក្រមលែងលះនោះហើយ កូនក្តីរបស់ខ្លួនពុំបានចូលរួមសងបំណុលដែលជំពាក់នោះទេ ដោយហេតុថា ដើមចោទបានទទួលផលពីការជួលផ្ទះ៣ល្វែងប្រចាំខែ ។

គ.២.២.អំពីការទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០(មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុន ធឿន បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីរបស់ខ្លួនសុំបដិសេធការទាមទារចំណុចនេះ ដោយហេតុថា កូនក្តីខ្លួនពុំមានលទ្ធភាពនោះទេ ហើយដើមចោទក៏ពុំមានភស្តុតាងណាមួយមកបញ្ជាក់ផងដែរ ។

គ.២.៣.អំពីការទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុន ធឿន បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ សុំបដិសេធចំពោះការកែប្រែចំណុចនេះ ដោយហេតុថា ការកែប្រែកម្មវត្ថុត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**ឃ.ការពិនិត្យភស្តុតាង**

**ឃ.១.ការពិនិត្យភស្តុតាងដែលផ្តល់ឱ្យតុលាការពិនិត្យដោយដើមចោទ**

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ (ថតចម្លងចំនួន ០១ច្បាប់) ។

-តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គលរបស់ឈ្មោះ [redacted] គឹមមួយ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ (ថតចម្លងចំនួន ០១ច្បាប់) ។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ (ថតចម្លងចំនួន ០១ច្បាប់) ។

-តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គលរបស់ឈ្មោះ [redacted] គឹមមួយ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ (ថតចម្លងចំនួន ០១ច្បាប់) ។

-តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គលរបស់ឈ្មោះ [redacted] គឹមមួយ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ (ថតចម្លងចំនួន ០១ច្បាប់) ។

-សាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប (ថតចម្លងចំនួន ០១ច្បាប់) ។

-លិខិតបញ្ជាក់ពីការរួចបំណុល ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ (ថតចម្លងចំនួន ០១ច្បាប់) ។

**ឃ.២.ការពិនិត្យភស្តុតាងដែលផ្តល់ឱ្យតុលាការពិនិត្យដោយចុងចម្លើយ**

-កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ (ថតចម្លងចំនួន ០១ច្បាប់) ។

-កិច្ចសន្យាប្រគល់លុយផ្តាច់ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ (ថតចម្លងចំនួន ០១ច្បាប់) ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការសាកសួរ និងការពិនិត្យភស្តុតាងនានាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា ៖

ពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ របស់លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដូច្នេះតុលាការគប្បីមានសមត្ថកិច្ចទទួលយកមកវិនិច្ឆ័យលើបណ្តឹងនេះ ស្របតាមបញ្ញត្តិមាត្រា៧ មាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

១.ចំណុចស្តីពីការទាមទារឱ្យចុងចម្លើយសងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ

១.១. ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] គឹមមួយ និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានបញ្ជាក់ថា ដើមចោទបានលែងលះគ្នាពីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ហើយតុលាការបានសម្រេចឱ្យដើមចោទ និងចុងចម្លើយសងបំណុលម្នាក់ពាក់កណ្ដាល ។ បច្ចុប្បន្នដើមចោទបានសងបំណុលរួចរាល់អស់ហើយ ទើបដើមចោទសុំទាមទាមប្រាក់ចំនួន ១៧,៩៦៧.១២៥(មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក ពីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ព្រោះតាំងពីពេលដែលចុងចម្លើយលែងលះជាមួយដើមចោទ ចុងចម្លើយបានឈប់សងបំណុលធនាគារទាំងអស់ ហើយដើមចោទជាអ្នកទទួលបន្ទុកសងបំណុលទាំងអស់ ថែមទាំងការប្រាក់ទៀតផង ។ ការអះអាងចំណុចនេះចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍បដិសេធដោយហេតុថា បំណុលសរុបទាំងអស់បានមកពីការខ្ចីធនាគារចំនួន២លើក ដោយលើកទី១ ខ្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីយកទៅជួលផ្ទះ និងជួសជុលផ្ទះសម្រាប់ធ្វើអាជីវកម្ម និងលើកទី២ ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ចុងចម្លើយពុំបានចូលរួមខ្ចីនោះទេ ដោយហេតុថា សាច់ប្រាក់ដែលទទួលបានពីធនាគារ គឺវេរចូលទៅក្នុងគណនីផ្ទាល់ខ្លួនរបស់ដើមចោទតែម្នាក់ឯង ហើយប្រាក់នេះដើមចោទបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួនមិនមានអ្វីពាក់ព័ន្ធនឹងចុងចម្លើយនោះទេ ។ ជាមួយគ្នានេះដែរ នៅពេលដែលកិច្ចសន្យាជួលផ្ទះបានបញ្ចប់ ចុងចម្លើយបានចាកចេញពីផ្ទះជួលដោយពុំបានយកអ្វីមកជាមួយនោះទេ ដោយទុកកុំព្យូទ័រចំនួន ១០ (ដប់) គ្រឿងឱ្យដើមចោទ ហើយចុងចម្លើយសុំមិនទទួលខុសត្រូវលើការសងបំណុលនោះទេ ដោយហេតុថា ពេលបញ្ចប់កិច្ចសន្យាជួលផ្ទះដើមចោទបានទទួលប្រាក់កក់ត្រឡប់មកវិញពីម្ចាស់ផ្ទះជួល ដែលមានចំនួន ៥.៤៣៧,៥១ (ប្រាំពាន់បួនរយសាមសិបប្រាំពីរ និងហាសិបមួយសេន) ដុល្លារអាមេរិក ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យាប្រគល់លុយផ្ដាច់ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ។ លើសពីនេះ ដើមចោទទទួលបានប្រាក់ពីការជួលផ្ទះ៣ល្វែងចំនួន ៣៦ (សាមសិបប្រាំមួយ) ខែ ស្មើនឹងទឹកប្រាក់ចំនួន ១៦.២០០ (មួយម៉ឺនប្រាំមួយពាន់ពីររយ) ដុល្លារអាមេរិក ហើយដើមចោទទទួលបានការអនុគ្រោះពីម្ចាស់ផ្ទះជួលក្នុងមួយខែចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក ក្នុងរយៈពេល០៣ (បី) ឆ្នាំចុងក្រោយនេះ ដែលស្មើនឹងទឹកប្រាក់ចំនួន ៥.៤០០ (ប្រាំពាន់បួនរយ) ដុល្លារអាមេរិក ដោយសរុបទាំងអស់ដើមចោទទទួលបានប្រាក់ចំនួន ២៧.០៣៧,៥១ (ពីរម៉ឺនប្រាំពីរពាន់សាមសិបប្រាំពីរ និងហាសិបមួយសេន) ដុល្លារអាមេរិក ដែលចំនួនទឹកប្រាក់សរុបនេះគឺលើសពីចំនួនប្រាក់ដែលដើមចោទបានទាមទារទៅទៀត ។ បន្ទាប់ពីតុលាការចេញសាលក្រមលែងលះនោះហើយ ចុងចម្លើយពុំបានចូលរួមសងបំណុលដែលជំពាក់នោះទេ ដោយហេតុថា ដើមចោទបានទទួលផលពីការជួលផ្ទះ៣ល្វែងប្រចាំខែ ។ ការអះអាងរបស់ចុងចម្លើយ និងអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយមិនមាន  ភស្តុតាងណាមួយមកបញ្ជាក់នោះទេ ។ លើសពីនេះទៅទៀត ផ្អែកតាមឯកសារជាភស្តុតាងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨, កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩, សាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប និងលិខិតបញ្ជាក់ពីការរួចបំណុល ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ដែលដើមចោទបានដាក់ជូន

តុលាការពិនិត្យឃើញថា កិច្ចសន្យាខ្ចីបរិភោគមានស្នាមមេដៃរបស់ចុងចម្លើយដែលបានផ្តិតមេដៃលើកិច្ចសន្យានោះផងដែរ នេះអាចបញ្ជាក់បានថា ចុងចម្លើយបានចូលរួមក្នុងការខ្ចីបំណុលពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ប្រាកដមែន ។ ហេតុនេះ នាំឱ្យតុលាការទទួលស្គាល់បានថា ដើមចោទឈ្មោះ [redacted] គឹមមួយ និងចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ពិតជាមានបំណុលរួមដែលបានជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងត្រូវបានសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ដោយសេចក្តីសម្រេចបញ្ចប់ចំណុចទី២ បានសម្រេចថា បំណុលរួម រួមមានប្រាក់ជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងបំណុលក្រៅពីជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សរុបចំនួន ២៥.៩៥០ (ពីរម៉ឺនប្រាំពាន់ប្រាំបួនរយហាសិប) ដុល្លារអាមេរិក ប្រាកដមែន ។

១.២. តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ និងអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានអះអាងថា ការខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីទៅជួលផ្ទះ ហើយបន្ទាប់ពីបញ្ចប់កិច្ចសន្យាជួលផ្ទះ ម្ចាស់ផ្ទះបានប្រគល់ប្រាក់កក់ត្រឡប់មកឱ្យដើមចោទវិញ ដែលមានចំនួន ៥.៤៣៧,៥១ (ប្រាំពាន់បួនរយសាមសិបប្រាំពីរ និងហាសិបមួយសេន) ដុល្លារអាមេរិក ។ ការអះអាងចំណុចនេះឃើញថា ពុំមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាប្រគល់លុយផ្តាច់ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ដែលចុងចម្លើយបានដាក់ជូនតុលាការពិនិត្យនោះទេ ដោយហេតុថា នៅក្នុងកិច្ចសន្យាប្រគល់លុយផ្តាច់ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ បានបញ្ជាក់ថា ឈ្មោះ [redacted] មៀន និងឈ្មោះ [redacted] សាមឿន បានប្រគល់ប្រាក់ទៅឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ ចំនួន ៥.៤៣៧,៥១ (ប្រាំពាន់បួនរយសាមសិបប្រាំពីរ និងហាសិបមួយសេន) ដុល្លារអាមេរិក ដើម្បីជួសជុលផ្ទះ ដែលប្រាក់នេះមិនមែនជាប្រាក់កក់ដូចដែលចុងចម្លើយ និងអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានអះអាងនោះទេ ហើយនៅក្នុងកិច្ចសន្យានេះក៏ពុំមានឈ្មោះរបស់ចុងចម្លើយនៅលើកិច្ចសន្យាផងដែរ ។

១.៣.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] គឹមមួយ បានអះអាងថា ដើមចោទឈ្មោះ [redacted] គឹមមួយ បានលែងលះគ្នាពីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ហើយតុលាការបានចេញសាលក្រមលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ដោយបានសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា ព្រមទាំងឱ្យដើមចោទ និងចុងចម្លើយរួមគ្នាសងបំណុលរួមពាក់កណ្តាលម្នាក់ ។ ក្រោយមកចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចសងប្រាក់ទៅឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតនោះទេ ដោយដើមចោទជាអ្នកទទួលបន្ទុកសងបំណុលតែម្នាក់ឯង ហើយចុងចម្លើយក៏បានអះអាងទទួលស្គាល់ថា ខ្លួនពុំបានសងបំណុលទៅឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតនោះទេ តែខ្លួនបានប្រគល់ប្រាក់ដែលទទួលបានពីការជួលផ្ទះចំនួន៣ល្វែងទៅឱ្យដើមចោទទាំងអស់ ។ ចំពោះការអះអាងរបស់ចុងចម្លើយថាបានប្រគល់ប្រាក់ដែលបានពីការជួលផ្ទះចំនួន០៣ល្វែងទៅឱ្យដើមចោទ ឃើញថា មិនមានភស្តុតាងណាមួយមកបញ្ជាក់ ដែលអាចនាំឱ្យតុលាការជឿបានថា មានប្រាក់ចំណូលដែលបានមកពីការជួលផ្ទះចំនួន០៣ល្វែង និងចុងចម្លើយបានប្រគល់ប្រាក់ដែលបានមកពីការជួលផ្ទះឱ្យទៅដើមចោទឈ្មោះ [redacted] គឹមមួយ ឡើយ ។ ហេតុនេះ



Scanned with CamScanner

តុលាការយល់ឃើញថា សេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និងសេចក្ដីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] គឹមមួយ មានភាពស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងដែលសាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប, តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គលរបស់ឈ្មោះ [redacted] គឹមមួយ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨, តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គលរបស់ឈ្មោះ [redacted] គឹមមួយ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩, តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គលរបស់ឈ្មោះ [redacted] គឹមមួយ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ និងលិខិតបញ្ជាក់ពីការរួចបំណុល ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ដែលបានបង្ហាញថា ចុងចម្លើយពិតជាពុំបានអនុវត្តកាតព្វកិច្ចក្នុងការសងបំណុលរួមពាក់កណ្ដាល ដែលបានសម្រេចដោយសាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ហើយដើមចោទឈ្មោះ [redacted] គឹមមួយ ពិតជាបានបង់ផ្ដាច់ប្រាក់ជំពាក់ទៅឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ដោយរួមមានប្រាក់ដើមចំនួន ៣៥,៩៣៤.២៥ (បីម៉ឺនប្រាំពាន់ប្រាំបួនរយសាមសិបបួន និងម្ភៃប្រាំសេន) ដុល្លារអាមេរិក តែម្នាក់ឯងប្រាកដមែន ។ ហេតុនេះ នាំឱ្យដើមចោទមានសិទ្ធិទាមទារតាមផ្លូវច្បាប់ក្នុងការប្ដឹងទាមទារឱ្យចុងចម្លើយសងប្រាក់នូវចំណែកពាក់កណ្ដាលដែលមានចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក មកឱ្យខ្លួនវិញ តាមបញ្ញត្តិមាត្រា៩៣២ នៃក្រមរដ្ឋប្បវេណី ។

២.អំពីការទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ

តាមសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និងសេចក្ដីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] គឹមមួយ បានទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឃើញថា ការប្ដឹងទាមទារនេះដោយហេតុថាជាកំហុសរបស់ចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ដែលពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសងបំណុលស្របទៅតាមសេចក្ដីសម្រេចបញ្ចប់របស់សាលក្រមរដ្ឋប្បវេណីលេខ ០៥ "ឈ" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ដែលបានសម្រេចឱ្យដើមចោទ និងចុងចម្លើយសងបំណុលរួមគ្នាពាក់កណ្ដាលម្នាក់ ។ ចំណុចនេះឃើញថា ការទាមទាររបស់ដើមចោទមានលក្ខណៈច្រើនលើសលប់ ដែលតុលាការគប្បីធ្វើការពិចារណា និងសម្រេចតាមស្ថានភាពជាក់ស្ដែង និងផ្អែកតាមកត្តាជីវភាពរបស់ចុងចម្លើយ ។

៣.អំពីការទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្ត ដោយអនុលោមទៅតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដូច្នេះ គប្បីតុលាការសម្រេចឱ្យចុងចម្លើយជាអ្នកទទួលប្រាក់ប្រដាប់ក្ដី ។

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន សងប្រាក់ចំនួន ១៧,៩៦៧.១២៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបប្រាំពីរ និងមួយរយម្ភៃប្រាំសេន) ដុល្លារអាមេរិក ទៅឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ ។

២.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន សងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ទៅឱ្យដើមចោទឈ្មោះ [redacted] គឹមមួយ ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

សៀមរាប,ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]